# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៧ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

ការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០ អនក្រ.បក

ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១ :** បញ្ចូល "អាជ្ញាធរប្រេងកាតជាតិកម្ពុជា" ជាសមាជិកបន្ថែម របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា២:** បញ្ជាក់លំអិតពីលើភារកិច្ច ដូចមានកំណត់ក្នុងមាត្រា ១៦ នៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ត្រង់ចំនុចទី១ ទៅខ្លឹមសារដូចខាងក្រោម :

"ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសំរេចលើគំរោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាព រុករក - ស្រាវជ្រាវ - ធ្វើអាជីវកម្ម

ប្រេងកាត - ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីតំរោងខ្លះ មិនត្រូវបានទទួលការលើកទឹកចិត្ត ក៏ដោយ ។

**មាត្រា៣:** ក្រៅពីនេះ ខ្លឹមសារនៃអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ នៅរក្សាទុកជាធរមានដដែល ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធនឹងអនុក្រឹត្យនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០២*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានជំរាបជូន

សម្តេច នាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**ចម ប្រសិទ្ធ**

<u>ចំលងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- កាលប្បវត្តិ - ឯកសារ